**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៩-០០១ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើធានាចំរុងការតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុន ជារូបិយប័ណ្ណដុល្លារអាមេរិក

**ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨ /៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មាន ឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាននៃធនាគារជាតិនៃកម្ពុជា
- យោងតាមការសំរេច របស់អង្គប្រជុំគណៈកម្មការវិនិយោគទុនបំរុង នៃធនាគារជាតិនៃកម្ពុជា លើកទី ៣១ នាថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨

**សំ រេ ច**

**ប្រការ ១.-**

អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ១ខែ ៣ខែ ៦ខែ ១ឆ្នាំ ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនតាមអត្រា១/២ នៃ SIBOR (Singapore Inter-Bank Offered Rate) ។

**ប្រការ ២.-**

អត្រាការប្រាក់លើប្រាក់បញ្ញើទុនបំរុងកាតព្វកិច្ច (Reserve Requirement) ដែលត្រូវទទួលការប្រាក់ ត្រូវបានផ្តល់ជូនតាមអត្រា ១/២ នៃ SIBOR គិតលើមូលដ្ឋានមួយខែ ។

**ប្រការ ៣.-**

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ ខែ ។

**ប្រការ ៤.-**

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ 

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩

ទេសាភិបាល

**ជា-ចាន់តូ**

<u>កន្លែងទទួល:</u>

-ដូចប្រការ៥ " ដើម្បីអនុវត្ត "

-កាលប្បវត្តិ

-ឯកសារ

<u>ចម្លងជូន:</u>

-សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

-ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

-នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "